**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងទេសចរណ៍**

លេខ ០៣៤ ប្រក

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមីនា ឆ្នាំ ២០០៧

ចុះបញ្ជីចូល ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៧

# ប្រកាស
## ស្ដីពី
## ការបង្កើតឯកសណ្ឋាន និងផ្លាកសញ្ញាសំគាល់ របស់អធិការដ្ឋាន ក្រសួងទេសចរណ៍

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៧ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០០០ ស្ដីពីការកែសំរួលមុខងារ និងភារកិច្ច និង ការបង្កើតក្រុមអ្នកច្បាប់ និងនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងអាស៊ាន នៃក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ១០៧ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០២ ស្ដីពីការតម្លើងនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ របស់ក្រសួងទេសចរណ៍ ទៅជាអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- យោងប្រកាស លេខ ២១ ប្រក ចុះថ្ងៃទី ០៣ ខែកុម្ភៈ ឆ្នាំ ១៩៩៨ ស្ដីពីតួនាទី ភារកិច្ច សិទ្ធិ និង រចនាសម្ព័ន្ធ នៃអធិការដ្ឋាន របស់ក្រសួងទេសចរណ៍
- យោងប្រកាសលេខ ៥០ប្រក.រប ចុះថ្ងៃទី ១២ ខែកក្កដា ឆ្នាំ២០០១ ស្ដីពីការកែសំរួលរចនាសម្ព័ន្ធរបស់អធិការដ្ឋាន របស់ក្រសួងទេសចរណ៍
- យោងតាមការចាំបាច់ របស់ក្រសួងទេសចរណ៍

## សំរេច

**ប្រការ ១** : អនុញ្ញាត ឱ្យអធិការដ្ឋាន នៃក្រសួងទេសចរណ៍ រៀបចំឯកសណ្ឋាននិងផ្លាកសញ្ញាសំគាល់សំរាប់មន្ត្រីអធិការដ្ឋាន ប្រើប្រាស់ក្នុងពេលធ្វើអធិការកិច្ចលើវិស័យទេសចរណ៍ ក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២** : ឯកសណ្ឋាន និងផ្លាកសញ្ញាសំគាល់ របស់អធិការដ្ឋានត្រូវបានកំណត់ដូចតទៅ :

**១. ឯកសណ្ឋាន :**

**ក. ចំពោះបុរស :**

**✱ មួកការ៉ែត្តមានបីថ្នាក់ :**

**- ថ្នាក់ដឹកនាំអធិការដ្ឋាន :**

**មួកការស្កេត** ពណ៌ខៀវចាស់ ផលិតអំពីក្រណាត់គេហ្គាលឡែន ដែលផ្នែកខាងមុខលើកណ្តាប់វីណ្ណមានភ្ជាប់រូបព្រះសង្ការពណ៌មាសបញ្ឈរទំហំ កំពស់ ៧,៨ ស.ម ទទឹង៦,៨ ស.ម ប៉ែកខាងក្រោមនៃជើងមួកនិងក្រោមព្រះសង្ការមានកណ្តាប់វីណ្ណ ធ្វើពីក្រណាត់ឡែនពណ៌ផ្ទៃមេឃព័ទ្ធជុំវិញ ។ ខាងក្រោមកណ្តាប់វីណ្ណប៉ែក ខាងមុខមានក្បាំងពណ៌ខ្មៅ ។ ផ្នែកខាងមុខក្រោមកណ្តាប់វីណ្ណ ដែលនៅពីលើក្បាំង មានកំរងខ្សែសយក្រង ពណ៌មាសចំនួន ៦សរសៃ ព្រមទាំងនៅចុងខ្សែទាំងពីរខាងភ្ជាប់ដោយឡេវព្រះសង្ការពណ៌មាស ។ នៅលើក្បាំង មួកមានប៉ាក់ក្បាច់ភ្ញីទេសឱ្ធនពណ៌មាស មានទំរង់ស្វែងក្របីដល់ជើងមួក ។

**- ថ្នាក់ការិយាល័យអធិការដ្ឋាន :**

**មួកការស្កេត** មានគំរូដូចថ្នាក់ដឹកនាំអធិការដ្ឋាន តែខុសត្រង់ កំរងខ្សែសយក្រងពណ៌មាស មានតែ ៤សរសៃ នៅលើក្បាំងមួកមានប៉ាក់ក្បាច់ភ្ញីទេសឱ្ធនពណ៌មាសទំរង់ស្វែងក្របី ដោយចុងសងខាងទុកចន្លោះ ៤ ស.ម ពីជើងមួក ។

**- ថ្នាក់មន្ត្រីអធិការដ្ឋាន :**

**មួកការស្កេត**មានគំរូដូចថ្នាក់ការិយាល័យ តែខុសត្រង់នៅលើជាយក្បាំងមួក មានវីណ្ណទំហំ៥ម.ម ពណ៌មាសព័ទ្ធវង់ដល់ជើងមួក ។

✱ អាវមានពីរថ្នាក់ :

**- ថ្នាក់ដឹកនាំអធិការដ្ឋាន :**

**អាវវ៉េស្តុ** ពណ៌ស សាច់ក្រណាត់គេហ្គាលឡែន បើក ក ថ្នេរបង្កប់មានហោប៉ៅ ៤ ដេរប៉ះពីលើ បត់ផ្នត់កណ្តាល មានគំរបរាងបួនជ្រុងទ្រវែង ប៊ិតជ្រុងសងខាង នៅខ្នងអាវដេរពុះចំកណ្តាលកាត់ ស្រុងវែង ជើងត្រង់ ដាក់ក្រៅខោ គ្មានផែកខ្នង ។

**- ថ្នាក់ការិយាល័យ និងថ្នាក់មន្ត្រីអធិការដ្ឋាន :**

**អាវដៃវែង** ពណ៌ស សាច់ក្រណាត់គេហ្គាលឡែន កឧប ថ្នេរឧប មានប៉ូលស្មា ហោប៉ៅពីរ ដេរប៉ះពីលើ បត់ផ្នត់កណ្តាល មានគំរបរាងបួនជ្រុងទ្រវែង ប៊ិតជ្រុងសងខាង កាត់ស្រុងវែង ជើងត្រង់ដាក់ក្នុងខោ ។

**✱ ខោបែបសកលមានមួយថ្នាក់ :**

**ខោជើងវែង** ពណ៌ខៀវចាស់ សាច់ក្រណាត់គេហ្គាលឡែន ចង្កេះត ថ្នេរបង្កប់ ជីបភ្លីខាងមុខពីរ មានហោប៉ៅបី ហោប៉ៅចំហៀងពីរដេរបញ្ឆិត និង ហោប៉ៅក្រោយមួយដេរបង្កប់គ្មានគំរប ។

**✱ ខ្សែក្រវ៉ាត់** ស្បែកពណ៌ខ្មៅ ក្បាលខ្សែក្រវ៉ាត់ពណ៌មាស ។

**✱ ស្បែកជើងមានមួយថ្នាក់ :**

**ស្បែកជើងឃ្លុប** ស្បែកពណ៌ខ្មៅ កខ្លី ចងខ្សែ និងស្រោមជើងពណ៌ខ្មៅ ។

**ខ. ចំពោះនារី :**

**មួកការស្កេត អាវ** មានគំរូតាមថ្នាក់ដូចបុរសដែរ ប៉ុន្តែខុសត្រង់អាវរបស់នារីកាត់ជីបរាង តាមដងខ្លួននារី ជើងត្រង់ ដាក់ក្នុងសំពត់ ។ ចំពោះនារីជាថ្នាក់ទាយកដ្ឋានអាវដាក់ក្រៅសំពត់ ។

**សំពត់សំឡុយបត់** ពណ៌ខៀវចាស់ សាច់ក្រណាត់គេហ្គាលឡែន មានសំរុងត្រឹមលើភ្នែកគោលនៃស្មងជើង ពី ១០ ទៅ ១៥ ស.ម អនុលោមទៅតាមមាឌនិងកំពស់របស់នារី ។

**ស្បែកជើងស្បែក** ពណ៌ខ្មៅ ឃ្លុបមុខ ឃ្លុបក្រោយ មានកែងទាប ។

**២. ផ្លាកសញ្ញាសំគាល់ :**

ផ្លាកសញ្ញាសំគាល់ ត្រូវបានកំណត់ដូចខាងក្រោម :

**ក. ផ្លាកសញ្ញាក្រសួងទេសចរណ៍ :**

កំណត់យករូបសញ្ញាក្រសួងទេសចរណ៍ ប៉ាក់ពីលើសាច់ក្រណាត់ដោយអំបោះពណ៌ រាងមូលទំហំ បន្ទាត់ផ្ចិត ៨ ស.ម ដេរភ្ជាប់ពីលើដើមដៃអាវខាងស្តាំ ។

**ខ. ផ្លាកសញ្ញាអធិការដ្ឋាន :**

កំណត់យករូបសញ្ញាអធិការដ្ឋាន មានរាងមូល លំអដោយរូបកណ្តាលនៃសញ្ញាក្រសួងទេសចរណ៍ ធ្វើអំពីលោហធាតុ រាងមូលប៉ោងឡើង ភ្ជាប់ដោយបន្ទះស្បែកពណ៌ "ស "ទំហំបន្ទាត់ ផ្ចិត ៥ ស.ម សំរាប់ព្យួរលើហោប៉ៅអាវខាងស្តាំ ។ នៅផ្ទៃរង្វង់ខាងលើពណ៌ខៀវមានសរសេរ អក្សរខ្មែរ ពណ៌សថា " **អធិការកិច្ច ទេសចរណ៍** " នៅផ្ទៃរង្វង់ខាងក្រោមពណ៌ខៀវមានសរសេរអក្សរឡាតាំង ពណ៌ "ស" ថា " **TOURISM INSPECTION** " ចុងវិជ្ជមាត្រទាំងសងខាង មានលំអដោយផ្កាចាន់ និងព័ទ្ធជុំវិញ ដោយខ្សែរង្វង់ តូច ធំ ពណ៌មាស ។

**គ. ផ្លាកសំគាល់ឈ្មោះ :**

កំណត់យកផ្លាករាងបួនជ្រុងទ្រវែង ទំហំ បណ្តោយ ១០ ស.ម ទទឹង ២,៥ ស.ម ធ្វើអំពីជាតិជ័ររឹង ។ ផ្ទៃខាងក្នុងមានពណ៌ខៀវចាស់ ព័ទ្ធជុំវិញដោយខ្សែបន្ទាត់ស្តើង ពណ៌ "ស" ។ មួយភាគបួន ផ្នែកខាងមុខ នៃផ្លាកទាំងមូលមានរូបសញ្ញាអធិការដ្ឋាន។ បីភាគបួននៃរូបសញ្ញាមានពុះចំពាក់កណ្តាល ដោយខ្សែបន្ទាត់ ស្តើងពណ៌ "ស" ។ ផ្នែកខាងលើមានសរសេរឈ្មោះមន្ត្រីនៃអធិការដ្ឋានជាអក្សរខ្មែរពណ៌ "ស"និងខាងក្រោម មានសរសេរឈ្មោះជាអក្សរឡាតាំង មានទំហំតូចជាងអក្សរខ្មែរ សំរាប់ខ្ទាស់លើគំរបហោប៉ៅអាវខាងស្តាំ ។

**ប្រការ ៣ :** មន្ត្រីអធិការដ្ឋានម្នាក់ៗ ត្រូវទទួលបានឯកសណ្ឋាន ដូចមានកំណត់ក្នុងប្រកាសនេះ ចំនួនពីរសំរាប់ ជារបប ប្រចាំឆ្នាំ ។

**ប្រការ ៤ :** ក្នុងពេលចុះធ្វើអធិការកិច្ច មន្ត្រីអធិការដ្ឋាន ត្រូវស្លៀកពាក់ឯកសណ្ឋាន ពាក់ផ្លាកសញ្ញាសំគាល់ និងត្រូវមាន លិខិតបញ្ជាបេសកកម្មជាប់តាមខ្លួនជានិច្ច។ ក្នុងពិធីប្រជុំ ឬពីធីផ្សេងៗទៀតបើចាំបាច់ ត្រូវស្លៀកពាក់ឯក សណ្ឋាន និងសញ្ញាសំគាល់នេះ។

**ប្រការ ៥ :** ជនណាក្លែងបន្លំស្លៀកពាក់ឯកសណ្ឋាន និងសញ្ញាសំគាល់ ដូចមានចែងក្នុងប្រការ ២ ត្រូវផ្តន្ទាទោសតាម ច្បាប់ជាធរមាន ។

**ប្រការ ៦ :** អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកទេសចរណ៍ នាយកខុទ្ទកាល័យ អធិការ ប្រធានក្រុមអ្នកច្បាប់ ប្រធានមន្ទីរទេសចរណ៍ខេត្តក្រុង ត្រូវទទួលបន្ទុកអនុវត្តតាមខ្លឹមសារប្រកាសនេះ អោយមានប្រសិទ្ធិភាព តាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ៧ :** ប្រកាសនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ចំលងជូន :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន ពាក់ព័ន្ធ
- គ្រប់សាលាខេត្ត ក្រុង
- ដូចក្នុងប្រការ ៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

រដ្ឋមន្ត្រី

ក្រសួងទេសចរណ៍

ឡាយ-ព្រហ្មស្ត

# ឯកសណ្ឋានថ្នាក់ដឹកនាំ នៃអធិការដ្ឋាន ក្រសួងទេសចរណ៍



# ឯកសណ្ឋានថ្នាក់ការិយាល័យមន្ត្រី នៃអធិការដ្ឋាន
# ក្រសួងទេសចរណ៍



# ឯកសណ្ឋានថ្នាក់ដឹកនាំ នៃអធិការដ្ឋាន
# ក្រសួងទេសចរណ៍



22/3/7

# ឯកសណ្ឋានថ្នាក់ការិយាល័យមន្ត្រី នៃអធិការដ្ឋាន
# ក្រសួងទេសចរណ៍



# គំរូមួកកាស្កេត



ថ្នាក់ដឹកនាំអធិការដ្ឋាន



ថ្នាក់ការិយាល័យ



មន្ត្រី

# ផ្លាកសញ្ញាសំគាល់

## ផ្លាកសញ្ញា ក្រសួងទេសចរណ៍




## រូបសញ្ញា អធិការដ្ឋាន




## ផ្លាកឈ្មោះ




22/3/7